ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
............,...

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៦២/ ១៩.៤.២០០៦
សាលដីកា
លេខ: ១៩១«ខ» /០៥.១១.២០០៩

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទីប្រាំ ខែវិច្ឆិកា ឆ្នាំ២០០៩ ដោយមានសមាសភាពដូចតទៅ:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជី</u>**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ២៦២ ចុះថ្ងៃទី១៩ខែមេសា ឆ្នាំ២០០៦ រវាង ៖

ជនជាប់ចោទឈ្មោះ [redacted] លូស ហៅ [redacted] លូស ភេទប្រុស អាយុ៣៦ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើតនៅ [redacted] ទីលំនៅមុនចាប់ខ្លួន [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) ប្រពន្ធឈ្មោះ [redacted] (ស) មានកូន០៥នាក់ ទោសពីមុនគ្មាន ឃុំខ្លួនថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។

មានមេធាវីការពារលោក [redacted] សុខា។

<u>ជាប់ចោទពីបទ:</u> ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិគៀនកែស២ ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ បទល្មើសមានចែងឲ្យផ្តន្ទាទោស តាមមាត្រា ៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោស។

**<u>ឯដំណើររឿងមានដូចតទៅ ៖</u>**

កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ វេលាម៉ោង៦ល្ងាច គឺឈ្មោះ [redacted] លូស ជាប្តីបានយកកាំបិត

១៩០

ចិតត្នោត ពីប្រពន្ធដែលកំពង់ចិតផ្លែឈើ បានយកកាំបិតនោះមកចាក់ ត្រូវប្រពន្ធឈ្មោះ [redacted] សេងគីម អាយុ៣២ឆ្នាំ ចំត្រង់លើក្បាលចំនួន០២កាំបិត និងចាក់ចំក្រោមក្លៀកឆ្វេងមួយកាំបិត បណ្ដាលឲ្យប្រពន្ធ ស្លាប់ភ្លាមនៅកន្លែងកើតហេតុ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៥៦ «ខ» ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១. ផ្ដន្ទាទោសដាក់ពន្ធនាគារលើឈ្មោះ [redacted] លូស ហៅ [redacted] លូស ភេទប្រុស អាយុ៣៦ឆ្នាំ កំណត់ ៥ (ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃឃុំខ្លួនថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥។

ពីបទ ធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តនៅភូមិកៀនកេស២ ឃុំគោកឃ្មុំ ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០២ និងមាត្រា៦៨ វាក្យខណ្ឌទី១ ចំណុចទី៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

២. វត្ថុតាងគឺ កាំបិតបន្ទូស ប្រវែង១,៣៨ ស.ម ចំនួន០១ ត្រូវរឹបអូសបំផ្លាញចោល។

៣. សាលក្រមនេះ ជំនុំជម្រៈ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] លូស ហៅ [redacted] លូស, បើកផ្លូវប្ដឹងឧទ្ធរណ៍កំណត់រយៈពេលពីរខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១០១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់លោកព្រះរាជអាជ្ញា ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៥៦«ខ» ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ត្រង់ចំណុចទី១ ដែលដាក់ពន្ធនាគារ ៥ឆ្នាំ ទាបជាងទោសក្នុងមាត្រា ៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការសាលាឧទ្ធរណ៍។

បានឃើញរបាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជី អានចម្លើយជនជាប់ចោទឈ្មោះ [redacted] លូស ហៅ [redacted] លូស ឆ្លើយនៅសាលាដំបូងខេត្តបាត់ដំបង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

យល់ឃើញថា បណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបាត់ដំបង មានលក្ខណៈត្រឹម ត្រូវ, ផ្អែកតាមមាត្រា៤ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ តម្រូវឲ្យផ្ដន្ទាទោស ពី១០ឆ្នាំ ទៅ១៥ឆ្នាំ និងវាក្យខណ្ឌទី២ តម្រូវឲ្យផ្ដន្ទាទោស ពី១៥ឆ្នាំ ទៅ២០ឆ្នាំ ឬ អស់មួយជីវិត។ ដោយសាលក្រមលេខ ៥៦ (ខ)៖

ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ ផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] លូស ហៅ [redacted] លូស ចំនួន០៥ឆ្នាំ ក្រោមអប្បបរមានៃទោសដែលកំរិតទោសនៃអំពើល្មើស តាមវាក្យខណ្ឌ២ ពី១៥ឆ្នាំ ទៅ២០ឆ្នាំ ឬ អស់មួយជីវិត ដូចនេះមហាអយ្យការសូមសន្និដ្ឋានសម្រេចតម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៦«ខ» ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ លើកលែងតែចំណុចទី១ នៃសាលក្រមស្តីពីការផ្តន្ទាទោសរបស់ជនជាប់ចោទ គប្បីផ្តន្ទាទោសតាមច្បាប់កំណត់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្នុងរឿងនេះ បើយើងពិនិត្យតាមអង្គហេតុ ទោះបីអំពើរបស់គាត់ប្រព្រឹត្ត ជាអំពើមនុស្សឃាតដោយចេតនាក៏ពិតមែន តែកូនក្តីខ្លួគាត់មានអាការៈមិនប្រក្រតី ស្មារតីរបស់ជនជាប់ចោទមិនហ្នឹងហ្នរ ហើយកំរិតវប្បធម៌របស់គាត់ទាប ម៉្យាងវិញទៀតគាត់ក៏បានសារភាពតាំងពីដំបូងមកម្លេះ ដូចនេះបញ្ជាក់បានថា គាត់មិនមានបំណងសម្លាប់ប្រពន្ធគាត់ទេ, សេចក្តីសម្រេចរបស់សាលាដំបូងសម្រេចត្រឹមត្រូវ សំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា វែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់។

២. តាមចម្លើយជនជាប់ចោទថា កាលពីថ្ងៃកើតហេតុ ដោយមានរឿងបន្តិចបន្តួចពីរឿងកូនចៅ ប្រពន្ធខ្លួនប្រកែកជាមួយខ្លួន ខ្លួនក៏ទះកាំភ្លៀង ២-៣ដៃ ដោយឈ្មោះ [redacted] លូន ជាបងឃាត់ ខ្លួនក៏ដើរចេញ តែដោយនឹកខឹងនឹងប្រពន្ធ(ជនរងគ្រោះ)ខ្លាំងពេក ខ្លួនក៏ស្ទុះទៅយកកាំបិតបន្ទោះនៅក្បែរចង្ក្រាន ហើយចាប់សក់ជនរងគ្រោះផ្ងើយឡើងលើ រួចចាក់មួយកាំបិតចំដើមទ្រូងខាងឆ្វេង ០១កាំបិតចំពោះ ដោយឃើញជនរងគ្រោះមិនស្លាប់ នៅដើរស្រែកខ្លាំងៗអោយគេជួយ ខ្លួនក៏កាប់ក្បាល០១កាំបិត និងចាក់០១កាំបិតថែមទៀត ទើបស្លាប់។

៣. តាមចម្លើយជនជាប់ចោទ នៅគ្រប់ដំណាក់កាល នៃការសួរឆ្លើយ បង្ហាញឲ្យឃើញជនជាប់ចោទមានសតិស្មារតី រឹងមាំ ដឹងនូវរាល់សម្មភាព ដែលខ្លួនប្រព្រឹត្ត។

៤. មានពិរុទ្ធលើជនជាប់ចោទ ពីបទ ឃាតកម្មដោយចេតនា ប្រព្រឹត្តនៅ ភូមិកៀនកែស២ ឃុំគោកឃ្មុំ

ស្រុកថ្មគោល ខេត្តបាត់ដំបង កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ៥៦«ខ» ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាដំបូង ខេត្តបាត់ដំបង សម្រេចមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ លើកលែងតែកម្រិតទណ្ឌកម្ម គួរកែប្រែឲ្យបានត្រឹមត្រូវឡើងវិញ ក្រៅពីនេះទុកនៅដដែល។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ១០១ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់លោកព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៥៦ «ខ» ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការ លើកលែងកម្រិតទណ្ឌកម្មលើជនជាប់ចោទ ត្រូវកែពី ៥ (ប្រាំ) ឆ្នាំ ទៅជា ១២ (ដប់ពីរ) ឆ្នាំ វិញ, ក្រៅពីនេះទុកនៅដដែល។

៣. បង្គាប់ឲ្យបន្តការឃុំខ្លួនជនជាប់ចោទ

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ កំបាំងមុខជនជាប់ចោទ ចំពោះមុខមេធាវីការពារជនជាប់ចោទ, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មក មន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

.............................................................................................................

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| ប្រធានសាលាឧទ្ធរណ៍ | ភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០១៤ |
| | ក្រឡាបញ្ជី |